ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ១១៧៥ សជណ

# សេចក្តីជូនដំណឹង

ក្រសួងមហាផ្ទៃ សូមជូនដំណឹងដល់សិស្ស-និស្សិត ដែលមានបំណងចូលបម្រើការងារនៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ ឲ្យបានជ្រាបថា ក្រសួងមហាផ្ទៃ សម្រេចបើកឲ្យមានការប្រឡងជ្រើសរើសសិស្ស-និស្សិត បញ្ចូលក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ សម្រាប់ឆ្នាំ២០១៦ ដើម្បីទៅបម្រើការងារនៅទីស្តីការក្រសួងមហាផ្ទៃ សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មណ្ឌលអប់រំកែប្រែ និងនៅពន្ធនាគារខេត្ត ដូចខាងក្រោម ៖

| ល.រ | អង្គភាព | ចំនួនក្របខ័ណ្ឌជ្រើសរើសសម្រាប់ឆ្នាំ ២០១៦ | | | | | មណ្ឌលប្រឡង |
|---|---|---|---|---|---|---|---|
| | | មន្ត្រីរដ្ឋបាលជាន់ខ្ពស់ | មន្ត្រីក្រមការ | លេខាធិការរដ្ឋបាល | មន្ត្រីពន្ធនាគារ | សរុប | |
| ១ | ទីស្តីការក្រសួង | ផ្នែករដ្ឋបាល : ១៥<br>ផ្នែកភាសាបរទេស : ០៦ | ១៤ | ១៤ | ១៥ | ៦៤ | រាជធានីភ្នំពេញ |
| ២ | ខេត្តកណ្តាល | ០៧ | ០៧ | ០៩ | ០៥ | ២៨ | |
| ៣ | រាជធានីភ្នំពេញ | ០៦ | ០៦ | ០៨ | ០០ | ២០ | |
| ៤ | ខេត្តកំពង់ចាម | ០៦ | ០៦ | ០៥ | ០៥ | ២២ | ខេត្តកំពង់ចាម |
| ៥ | ខេត្តស្វាយរៀង | ០៥ | ០៤ | ០៨ | ០០ | ១៧ | |
| ៦ | ខេត្តព្រៃវែង | ០៥ | ០៨ | ០៧ | ០០ | ២០ | |
| ៧ | ខេត្តត្បូងឃ្មុំ | ០៧ | ១២ | ១០ | ០០ | ២៩ | |
| ៨ | ខេត្តសៀមរាប | ០៨ | ០៧ | ១១ | ១២ | ៣៨ | ខេត្តសៀមរាប |
| ៩ | ខេត្តកំពង់ធំ | ០២ | ០២ | ០៤ | ០៥ | ១៣ | |
| ១០ | ខេត្តព្រះវិហារ | ០២ | ០៥ | ០៤ | ០០ | ១១ | |
| ១១ | ខេត្តឧត្តរមានជ័យ | ០៣ | ០២ | ០៤ | ០០ | ០៩ | |
| ១២ | ខេត្តបាត់ដំបង | ១៣ | ១១ | ១២ | ១០ | ៤៦ | ខេត្តបាត់ដំបង |
| ១៣ | ខេត្តកំពង់ឆ្នាំង | ០២ | ០២ | ០២ | ០០ | ០៦ | |
| ១៤ | ខេត្តប៉ៃលិន | ០២ | ០២ | ០៣ | ០០ | ០៧ | |
| ១៥ | ខេត្តពោធិ៍សាត់ | ០៣ | ០២ | ០៤ | ០០ | ០៩ | |
| ១៦ | ខេត្តបន្ទាយមានជ័យ | ០៣ | ០២ | ០៣ | ១០ | ១៨ | |
| ១៧ | ខេត្តព្រះសីហនុ | ០៣ | ០២ | ០៣ | ០០ | ០៨ | ខេត្តព្រះសីហនុ |
| ១៨ | ខេត្តកោះកុង | ០៤ | ០៣ | ០៤ | ០០ | ១១ | |
| ១៩ | ខេត្តកំពង់ស្ពឺ | ០២ | ០៣ | ០៣ | ០០ | ០៨ | |
| ២០ | ខេត្តក្រចេះ | ០៣ | ០៣ | ០៣ | ០០ | ០៩ | ខេត្តក្រចេះ |
| ២១ | ខេត្តស្ទឹងត្រែង | ០៣ | ០២ | ០៤ | ០០ | ០៩ | |
| ២២ | ខេត្តរតនគិរី | ០៣ | ០៣ | ០៤ | ០០ | ១០ | |
| ២៣ | ខេត្តមណ្ឌលគិរី | ០១ | ០២ | ០២ | ០០ | ០៥ | |
| ២៤ | ខេត្តកំពត | ០៤ | ០៣ | ០៤ | ០០ | ១១ | ខេត្តកំពត |
| ២៥ | ខេត្តតាកែវ | ០៦ | ០៦ | ០៧ | ០០ | ១៩ | |
| ២៦ | ខេត្តកែប | ០១ | ០១ | ០២ | ០០ | ០៤ | |
| | សរុប | ១២៥ | ១២០ | ១៤៤ | ៦២ | ៤៥១ | |

- មណ្ឌលប្រឡងត្រូវបានកំណត់ :

  ក/- **ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការ** កំណត់ឲ្យមាន ៧ មណ្ឌលប្រឡង :

| | | |
|---|---|---|
| **១- មណ្ឌលប្រឡងរាជធានីភ្នំពេញ** | : | សម្រាប់បេក្ខជនដាក់ពាក្យស្នើសុំបម្រើការងារនៅ ទីស្តីការក្រសួងមហាផ្ទៃ រាជធានីភ្នំពេញ និងខេត្តកណ្តាល ។ |
| **២- មណ្ឌលប្រឡងខេត្តកំពង់ចាម** | : | សម្រាប់បេក្ខជនដាក់ពាក្យស្នើសុំបម្រើការងារនៅ ខេត្តកំពង់ចាម ខេត្តស្វាយរៀង ខេត្តព្រៃវែង និងខេត្តត្បូងឃ្មុំ។ |
| **៣- មណ្ឌលប្រឡងខេត្តសៀមរាប** | : | សម្រាប់បេក្ខជនដាក់ពាក្យស្នើសុំបម្រើការងារនៅ ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ។ |
| **៤- មណ្ឌលប្រឡងខេត្តបាត់ដំបង** | : | សម្រាប់បេក្ខជនដាក់ពាក្យស្នើសុំបម្រើការងារនៅ ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងខេត្តបន្ទាយមានជ័យ។ |
| **៥- មណ្ឌលប្រឡងខេត្តព្រះសីហនុ** | : | សម្រាប់បេក្ខជនដាក់ពាក្យស្នើសុំបម្រើការងារនៅ ខេត្តព្រះសីហនុ ខេត្តកំពង់ស្ពឺ និងខេត្តកោះកុង ។ |
| **៦- មណ្ឌលប្រឡងខេត្តក្រចេះ** | : | សម្រាប់បេក្ខជនដាក់ពាក្យស្នើសុំបម្រើការងារនៅ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី ។ |
| **៧- មណ្ឌលប្រឡងខេត្តកំពត** | : | សម្រាប់បេក្ខជនដាក់ពាក្យស្នើសុំបម្រើការងារនៅ ខេត្តកំពត ខេត្តតាកែវ និងខេត្តកែប។ |

  ខ/- **ក្របខ័ណ្ឌលេខាធិការរដ្ឋបាល** កំណត់ឲ្យមាន ២៥ មណ្ឌលប្រឡង ស្ថិតនៅសាលារាជធានីភ្នំពេញ និងសាលាខេត្តទាំង ២៤ ដែលបេក្ខជនបានដាក់ពាក្យសុំបម្រើការងារ។

  ដោយឡែក**ក្របខ័ណ្ឌមន្ត្រីពន្ធនាគារ** មណ្ឌលប្រឡងត្រូវកំណត់ដូចខាងក្រោម៖

  - ស្ថិតនៅសាលាខេត្តចំនួន ០៦ ដែលមានកំណត់ជ្រើសរើសបេក្ខជនសរុបចំនួន ៤៧ នាក់ ដូចមានរៀបរាប់ក្នុងតារាងខាងលើ
  - ស្ថិតនៅសាលារាជធានីភ្នំពេញ សម្រាប់បេក្ខជនដាក់ពាក្យប្រឡងចូលបម្រើការងារនៅមណ្ឌលអប់រំកែប្រែទី ១
  - ស្ថិតនៅសាលាខេត្តត្បូងឃ្មុំ សម្រាប់បេក្ខជនដាក់ពាក្យប្រឡងចូលបម្រើការងារនៅមណ្ឌលអប់រំកែប្រែទី ៣។

បេក្ខជនដែលមានបំណងចូលបម្រើការងារនៅទីស្តីការក្រសួងមហាផ្ទៃ និងមណ្ឌលអប់រំកែប្រែទី ១ ត្រូវទៅដាក់ពាក្យសុំចុះឈ្មោះដើម្បីចូលរួមប្រឡងប្រជែងនៅការិយាល័យក្របខ័ណ្ឌ នាយកដ្ឋានបុគ្គលិក នៃអគ្គនាយកដ្ឋានរដ្ឋបាល ។

បេក្ខជនដែលមានបំណងចូលបម្រើការងារនៅតាមសាលារាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ មណ្ឌលអប់រំកែប្រែទី ៣ និងតាមពន្ធនាគារខេត្ត ត្រូវទៅដាក់ពាក្យសុំនៅតាមសាលារាជធានីភ្នំពេញ និងសាលាខេត្តសាមី នៅរៀងរាល់ម៉ោងធ្វើការចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ **ម៉ោង ១៧ : ០០ នាទី នាថ្ងៃសុក្រ ទី១៩ ខែសីហា ឆ្នាំ២០១៦ ជាកាលបរិច្ឆេទកំណត់ចុងក្រោយ** ។

កាលបរិច្ឆេទប្រឡង គឺនៅថ្ងៃ **អាទិត្យ ទី២៥ ខែកញ្ញា ឆ្នាំ២០១៦** ។

ព័ត៌មានលំអិតផ្សេងៗទៀត សូមអញ្ជើញទាក់ទងផ្ទាល់នៅតាមការិយាល័យទទួលពាក្យសុំចុះឈ្មោះប្រឡងនៅតាមទីកន្លែងដែលបានកំណត់ នៅរៀងរាល់ម៉ោងធ្វើការ ។

**រាជធានីភ្នំពេញ ថ្ងៃទី** ០៤ **ខែ**កក្កដា **ឆ្នាំ២០១៦**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងព័ត៌មាន
- ក្រសួងមុខងារសាធារណៈ

  (ដើម្បីជូនជ្រាប)
- សាលារាជធានី និងគ្រប់សាលាខេត្ត